# បាលីថេរគ្រឿងសក្ការៈមាឃបូជា

អជ្ជាយំ មាឃបុណ្ណមី សម្បត្តា មាឃនក្ខត្តេន យុត្តោ យត្ថ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ចាតុរង្គិកេ សាវកសន្និបាតេ ឱវាទបា្បតិមោក្ខំ ឧទ្ទិសិតទាហិ អឌ្ឍតេរសានិ សព្វេ សង្ឃេវ ខីណាសវានំ សព្វេ តេ ឯហិភិក្ខុ សព្វេបិ តេ អនាមន្តិតាវ ភគវតោ សន្តិកំ អាគតា វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមីយំ វឌ្ឍមានកច្ឆាយ តស្មិញ្ច សន្និបាតេ ភគវា វិសុទ្ធុបោសថ អកាសិ អយំ អម្ហាកំ ភគវតោ ឯកោ យេវ សាវកសន្និបាតោ អហោសិ ចាតុរង្គិកោ អឌ្ឍតេរសានិ ភិក្ខុ-សតានិ សព្វេ សង្ឃេវ ខីណាសវានំ មយន្ទានិ ឥមំ មាឃបុណ្ណមី នក្ខត្តសមយំ តក្កាលសទិសំ សម្បត្តា ចិរបរិនិព្វុតម្បិ តំ ភគវន្តំ អនុស្សរមានា ឥមស្មឹ តស្ស ភគវតោ សក្ខីភូតេ ចេតិយេ ឥមេហិ ទីបធូប បុប្ផាទិ សក្កាេហិ តំ ភគវន្តំ តានិ ច អឌ្ឍតេរសានិ ភិក្ខុសតានិ អភិបូជយាមិ សាធុ នោ ភន្តេ ភគវា សសាវកសង្ឃោ សុចិរបរិនិព្វុតោ្តា គុណេហិ ធរមានា ឥមេ សក្ការេ ទុគ្គត បណ្ណាការភូតេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

*ប្រែថា*៖ *ថ្ងៃនេះយើងខ្ញុំព្រះករុណាទាំងឡាយ បានមកជួបជុំគ្នាក្នុងទីកន្លែងនេះ ត្រូវនឹងថ្ងៃពេញបូណ៌មីខែមាឃ ព្រះចន្ទពេញវង់ ប្រកបដោយនក្ខត្តមាឃ ត្រូវនឹងថ្ងៃដែលព្រះតថាគត អរហំសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្ដែងនូវឱវាទប្បាតិមោក្ខ ក្នុងថ្ងៃដែលប្រជុំសាវកសង្ឃ ប្រកបដោយអង្គ៤ (ហៅថាចតុរង្គសន្និ-បាត) គ្រានោះព្រះភិក្ខុសង្ឃមានចំនួន១២៥០អង្គ សុទ្ធតែជាព្រះអរហន្តខីណាស្រព ព្រះភិក្ខុសង្ឃទាំងឡាយនោះ សុទ្ធសឹងជាឯហិភិក្ខុឧបសម្បទា បាននិមន្តមកជួបជុំគ្នា ក្នុងសំណាក់ព្រះបរមសាស្ដាចារ្យដោយឥតបានមត់កំណត់គ្នាទុកជាមុន ក៏ស្រាប់តែមកប្រជុំព្រមគ្នាតែម្ដង នៅចំពោះព្រះភ័ក្ត្រព្រះសម្មា-*



សម្ពុទ្ធក្នុងវត្តវេឡុវន វេលាថ្ងៃរសៀល ត្រូវនឹងថ្ងៃពេញបូណ៌មី ខែមាឃ ។ គ្រានោះព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ធ្វើកិច្ច វិសុទ្ធិឧបោសថ ហើយទ្រង់សម្តែងនូវឱវាទបា្បតិមោក្ខ ក្នុងទីប្រជុំសង្ឃសាវ័កនោះ ការប្រជុំសាវ័កសង្ឃនេះ ប្រកបដោយអង្គ៤ (ហៅថាចតុរង្គសន្និបាត) មានតែម្តងគត់ ក្នុងសាសនា របស់ព្រះដ៏មានព្រះភាគ រីឯព្រះភិក្ខុសង្ឃទាំង១២៥០អង្គនោះ សុទ្ធតែជាព្រះអរហន្តខីណាស្រពទាំងអស់ ។ ឥឡូវនេះ យើងខ្ញុំព្រះករុណាទាំងឡាយ បានមកជួបជុំគ្នានៅក្នុងថ្ងៃពេញបូណ៌មីខែមាឃ ដែលជាថ្ងៃនក្ខត្ត សម័យ ដ៏ចំឡែកអស្ចារ្យ នៃចតុរង្គសន្និបាត ដើម្បីរំឭកនឹកដល់ព្រះគុណដ៏ខ្ពង់ខ្ពស់នៃព្រះដ៏មាន ព្រះភាគអង្គនោះ សូម្បីព្រះអង្គព្រមទាំងព្រះអរហន្តសាវ័កទាំងឡាយបានចូលបរិនិព្វានអស់កាលជាយូរអង្វែងទៅហើយក្តី ក៏យើងខ្ញុំព្រះករុណាទាំងឡាយនៅតែគោរពជាចំពោះព្រះអង្គ ព្រមទាំងព្រះភិក្ខុសង្ឃជាអរហន្តសាវ័កទាំង ១២៥០អង្គនោះ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់នូវ គុណរបស់ព្រះអង្គ មានព្រះករុណាគុណជាដើម ។ យើងខ្ញុំទាំងឡាយ បាននាំយកមកនូវគ្រឿងសក្ការៈបូជា មានផ្កាភ្ញីធូបទៀនជាដើម យកមកតម្កល់ក្នុងសាលាបុណ្យនេះ ដើម្បីបូជាចំពោះព្រះអង្គ ។ បពិត្រព្រះសម្មាសម្ពុទ្ធដ៏ចំរើន ព្រមទាំងព្រះអរហន្តសាវ័កគ្រប់ព្រះអង្គ សូម្បីព្រះអង្គទ្រង់បរិនិព្វានអស់កាលជាយូរអង្វែងទៅហើយក្តី ប៉ុន្តែគុណរបស់ព្រះអង្គ នៅតែប្រាកដច្បាស់នៅឡើយ ព្រះអង្គបានតម្កល់ទុកនូវព្រះធម៌ឱ្យយើងខ្ញុំព្រះករុណាទាំងឡាយគោរពបូជារាល់ថ្ងៃ ។ ហេតុនេះហើយ សូមព្រះអង្គ ទ្រង់ព្រះមេត្តាទទួលយកនូវគ្រឿងសក្ការៈទាំងឡាយ មានផ្កាភ្ញីធូបទៀនជា ដើម ដែលខ្ញុំព្រះអង្គទាំងអស់គ្នាបានបូជាចំពោះទៅនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៏ ដើម្បី សេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំព្រះករុណាទាំង ឡាយផង អស់កាលជាយូរអង្វែងទៅហោង ៕

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុំ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២

